**ព្រះរាជាណាចក្រកម្ពុជា**
ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

# សេចក្តីជូនដំណឹង
## ស្តីពី
## លទ្ធផលសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨

នាថ្ងៃទី១៥ និង១៦ ខែកុម្ភៈ ឆ្នាំ២០១៧ នេះ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ នៃការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ២០១៤-២០១៨ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម បណ្ឌិត អ៊ិត សំហេង** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយមានការអញ្ជើញចូលរួមរបស់ឯកឧត្តម លោកជំទាវ រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ទីប្រឹក្សាអមក្រសួង អគ្គលេខាធិការ អគ្គនាយក តំណាងក្រសួងស្ថាប័ន ដៃគូអភិវឌ្ឍន៍ជាតិនិងអន្តរជាតិ និងមន្ត្រីរាជការថ្នាក់ជាតិនិងក្រោមជាតិរបស់ក្រសួង សរុបចំនួន ៤០០នាក់។ ក្នុងរយៈពេល ២ថ្ងៃនេះ អង្គសន្និបាតបានធ្វើបទបង្ហាញ បទអន្តរាគមន៍ និងពិភាក្សាលើប្រធានបទចំនួន៩ ព្រមទាំងបានឯកភាពកំណត់នូវលទ្ធផល និងទិសដៅការងារសំខាន់ៗដូចខាងក្រោម៖

**ក-លទ្ធផលការងារឆ្នាំ២០១៦**

**១-ការអភិវឌ្ឍលក្ខខណ្ឌការងារ និងសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ**

- សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីនៅក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈមានចំនួន ១១ ១៦៨គ្រឹះស្ថាន (កើន ៣៥%) និងមានកម្មករនិយោជិតចំនួន ១ ១៨៧ ២២៧នាក់ (ស្រី ៨៣១ ១០៤នាក់) គឺកើន ២២% ក្នុងនោះរោងចក្រវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងមានចំនួន ១ ១០៧ គ្រឹះស្ថាន គឺកើន 0,៧% និងមានកម្មករនិយោជិតចំនួន ៧៤៣ ៦១៥នាក់ (ស្រី ៦៤៣ ៧១៤នាក់) គឺកើន ១១% ព្រមទាំងបានផ្តល់ការងារដោយប្រយោលដល់ប្រជាពលរដ្ឋប្រមាណជាង ២លាននាក់ផ្សេងទៀត។
- បានចុះធ្វើអធិការកិច្ចការងារចំនួន ៨ ៧៦៣លើក (ថ្នាក់ជាតិចំនួន ២ ៤៤៦លើក និងរាជធានី ខេត្ត ៦ ៣១៧លើក) ក្នុងនោះអធិការកិច្ចការងារផ្នែកសិប្បកម្មឡជដ្ឋបានចំនួន ៣៧៩លើក កើន ៧៥% (ថ្នាក់ជាតិ ២៦លើក និងរាជធានី ខេត្ត ៣៥៣លើក) ដោយ៖



អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

- បានដាក់កំហិតសហគ្រាស គ្រឹះស្ថានចំនួន ៨៤២គ្រឹះស្ថាន (កើន ៣០%) ដោយបានផាកពិន័យចំនួន ៦០គ្រឹះស្ថាន (កើន ១០០%) ក្នុងនោះថ្នាក់ជាតិ ៥គ្រឹះស្ថាន និងរាជធានី ខេត្ត ៥៥គ្រឹះស្ថាន និងបានកំពុងរៀបចំចេញលិខិតផាកពិន័យចំនួន ៥១គ្រឹះស្ថាន ក្នុងនោះថ្នាក់ជាតិ ២៧គ្រឹះស្ថាន និងរាជធានី ខេត្ត ២៤គ្រឹះស្ថាន។
- បានដកហូត និងទប់ស្កាត់ពលកម្មកុមារចំនួន ៣ ៤២១នាក់។
- បានណែនាំម្ចាស់សិប្បកម្មឡឥដ្ឋឱ្យរៀបចំបែងចែកទីកន្លែងស្នាក់នៅរបស់កម្មករ ឱ្យដាច់ចេញពីទីតាំងសង្វាក់ផលិតកម្ម ដើម្បីចៀសវាងគ្រោះថ្នាក់ដាយថាហេតុណាមួយដល់កុមារដែលស្នាក់នៅជាមួយឪពុកម្តាយ ដែលអាចនាំឱ្យមានការយល់ច្រឡំថាជាពលកម្មកុមារនៅក្នុងសិប្បកម្មឡឥដ្ឋ។
- បានរកឃើញរោងចក្រ សហគ្រាស គ្រឹះស្ថាន ដែលមានគិលានដ្ឋាន បន្ទប់រំលួស និងប្រអប់សង្គ្រោះបឋមត្រឹមត្រូវតាមច្បាប់ចំនួន ៦០២សហគ្រាស (កើន ២០%)។

- បានរៀបចំអនុក្រឹត្យស្ដីពីឯកសណ្ឋាន សញ្ញាសម្គាល់ សញ្ញាសក្តិ និងបណ្ណសម្គាល់ខ្លួនរបស់មន្ត្រីអធិការកិច្ចការងារ។
- បានរៀបចំប្រកាសរួមស្ដីពីការផាកពិន័យជាប្រាក់ចំពោះអ្នកប្រព្រឹត្តល្មើសនឹងច្បាប់ស្ដីពីការងារ។
- បានអនុវត្តព្រះរាជក្រឹត្យលេខ នស/រកត/១១១៦/១០៤៤ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០១៦ ស្ដីពីការបង្កើតគណៈកម្មាធិការជាតិប្រឆាំងពលកម្មកុមារ និងបានបញ្ចប់សេចក្តីព្រាង ផែនការសកម្មភាពជាតិស្ដីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥។
- បានផ្សះផ្សា និងដោះស្រាយវិវាទការងារបុគ្គលនៅតាមសហគ្រាស គ្រឹះស្ថានចំនួន ១៤៨គ្រឹះស្ថាន (ថយ ១%) ក្នុងនោះថ្នាក់ជាតិ ២៦គ្រឹះស្ថាន និងរាជធានី ខេត្ត ១២២គ្រឹះស្ថាន ដែលគិតជាករណីគឺមានចំនួន ២១៦ករណី ក្នុងនោះថ្នាក់ជាតិ ៣៨ករណី និងរាជធានី ខេត្ត ១៧៨ករណី។ ជាលទ្ធផលគឺបានសះជាចំនួន ៨៩ករណី មិនសះជាចំនួន ១២៣ករណី និងមោឃៈចំនួន ៤ករណី។ មូលហេតុធំៗទាំង៥ នៃវិវាទការងារបុគ្គលគឺ លម្អៀងនៃការគិតប្រាក់ឈ្នួល ថិរវេលាធ្វើការ ការធ្វើការបន្ថែមម៉ោង ការឈប់សម្រាក និងការបញ្ឈប់ពីការងារ។
- បានផ្សះផ្សា និងដោះស្រាយវិវាទការងាររួមនៅតាមសហគ្រាស គ្រឹះស្ថានចំនួន ២៩៣គ្រឹះស្ថាន (ថយ ២៣%) ក្នុងនោះថ្នាក់ជាតិ ១២៩គ្រឹះស្ថាន និងរាជធានី ខេត្ត ១៦៤គ្រឹះស្ថាន ដែលគិតជាករណីគឺមានចំនួន ៦៣៧ករណី ក្នុងនោះថ្នាក់ជាតិ ១៣៤ករណី និងរាជធានី ខេត្ត ៥០៣ករណី ដោយពាក់ព័ន្ធនឹងកម្មករនិយោជិតចំនួន ១១៣ ៦២៧នាក់ (ថយ ១៣%) ក្នុងនោះថ្នាក់ជាតិ ៤៥ ០៥៥នាក់ និងរាជធានី ខេត្ត ៦៨ ៥៧២នាក់។ ជាលទ្ធផល គឺបានសះជាចំនួន ២៣០ករណី មិនសះជា ៤០៦ករណី និងមោឃៈចំនួន ១ករណី។ ដូចគ្នានឹងវិវាទការងារបុគ្គលដែរ មូលហេតុធំៗទាំង៥នៃវិវាទការងាររួមគឺ លម្អៀងនៃការគណនាប្រាក់ឈ្នួល ថិរវេលាធ្វើការ ការធ្វើការបន្ថែមម៉ោង ការឈប់សម្រាក និងការបញ្ឈប់ពីការងារ។

- បានបញ្ជូនករណីវិវាទទៅក្រុមប្រឹក្សាអាជ្ញាកណ្ដាលចំនួន ២៤៥ករណី (ថយ ២៧,៥%) ក្នុងនោះ៖
  - សះជា (ដោយភាគីជម្លោះ និងដោយក្រុមប្រឹក្សាអាជ្ញាកណ្ដាល) ចំនួន ៦០ករណី
  - ចេញសេចក្ដីបង្គាប់ចំនួន ១៤៨ករណី
  - មិនទាន់បានសវនាការចំនួន ៣៧ករណី
- កូដកម្មមានចំនួន ២១១រោងចក្រ (ថយ ៣៥%) ក្នុងនោះនៅរាជធានីភ្នំពេញមានចំនួន ១៤៧រោងចក្រ និងខេត្តចំនួន ៦៤រោងចក្រ ស្មើនឹង ២២០ករណី ដោយមានកូដករសរុបចំនួន ៥៤ ៩៧៨នាក់ និងបានដោះស្រាយសះជាចំនួន ២១៤ករណី។
- បានបញ្ចប់សេចក្ដីព្រាងអនុក្រឹត្យស្ដីពីការបង្កើតវិទ្យាស្ថានការងារ សម្រាប់ធ្វើវិក្រឹត្យការ និងបណ្ដុះបណ្ដាលដល់មន្ត្រីអធិការកិច្ចការងារឱ្យបំពេញនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងដល់សាធារណជន។
- បានរៀបចំអនុក្រឹត្យស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់គណៈកម្មាធិការជាតិសុខភាព និងសុវត្ថិភាពការងារ។
- បានពិនិត្យកាយសម្បទាកម្មករនិយោជិតចំនួន ២៤៥ ០៦០នាក់។
- បានសិក្សាសម្របសម្រួល និងសហការជាមួយអង្គការអន្តរជាតិខាងការងារ (ILO) ភាគីកម្មករនិយោជិត និងភាគីនិយោជក ដើម្បីពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើងសម្រាប់ឆ្នាំ២០១៧ ពីចំនួន ១៤០ដុល្លារអាមេរិក ទៅ ១៥៣ដុល្លារអាមេរិក (កើន ៩,៣%) ហើយបើគិតទាំងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗ អាចទទួលបានប្រាក់ចំណូលពី ១៧០ដុល្លារអាមេរិក ទៅ ១៨១ដុល្លារអាមេរិក ក្នុងមួយខែ។
- បានរៀបចំប្រកាសលេខ២៤៩ក.ប/ប្រ.ក ស្ដីពីការចុះបញ្ជីសហជីពនិងសមាគមនិយោជក ប្រកាសលេខ២៥០ក.ប/ប្រ.ក ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការអនុវត្តច្បាប់ស្ដីពីសហជីព ប្រកាសលេខ២៥១ក.ប/ប្រ.ក ស្ដីពីនីតិវិធីនៃការធ្វើឧបាស្រ័យលើចំណាត់ការរបស់មន្ត្រីដែលបានប្រតិភូកម្មមុខងារក្នុងការអនុវត្តច្បាប់ស្ដីពីសហជីព និងប្រកាសលេខ៣៦២ក.ប/ប្រ.ក ស្ដីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្ដឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចរចា។
- បានចុះបញ្ជីសហជីពមូលដ្ឋានចំនួន ១៦២សហជីព សហព័ន្ធសហជីពចំនួន ៦សហជីព និងសហភាពសហជីពចំនួន ២សហជីព។ គិតត្រឹមខែធ្នូ ឆ្នាំ២០១៦នេះ កម្ពុជាមានសហជីពមូលដ្ឋានកើនរហូតដល់ទៅចំនួន ៣ ៤៩៧សហជីព សហព័ន្ធសហជីពចំនួន ១០៣សហជីព សហភាពសហជីពចំនួន ១៨សហជីព និងសមាគមនិយោជកចំនួន ៨សមាគម។
- បានទទួលស្គាល់ប្រតិភូបុគ្គលិកចំនួន ១ ៦៩៨នាក់ ។
- បានទទួលស្គាល់ភាពជាតំណាងបំផុតចំនួន ៣៨សហជីព និងបានចុះបញ្ជីអនុសញ្ញារួមចំនួន ៤០អនុសញ្ញា។

## ២-ការអភិវឌ្ឍការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

- បានចុះបញ្ជីគ្រឹះស្ថានបណ្តុះបណ្តាលក្រោមឱវាទក្រសួងសរុបចំនួន ១១១គ្រឹះស្ថាន ក្នុងនោះគ្រឹះស្ថានសាធារណៈមានចំនួន ៣៩គ្រឹះស្ថាន។ គ្រឹះស្ថានបណ្តុះបណ្តាលសាធារណៈចំនួន ១២ ទទួលបានវិញ្ញាបនបត្រ ISO ពីស្ថាប័នអន្តរជាតិលើការគ្រប់គ្រង។
- បានបណ្តុះបណ្តាលកម្រិតឧត្តម មធ្យម និងបឋមលើជំនាញឧស្សាហកម្មបច្ចេកទេស សិប្បកម្ម សេវាកម្ម ទេសចរណ៍ និងកសិកម្ម ដល់សិស្សនិស្សិត និងសិក្ខាកាមសរុបចំនួន ៣២ ៨៩៩នាក់។
- បានបន្តរៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- បានចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ានដោយមានបេក្ខជនពីប្រទេសកម្ពុជាចំនួន ១៣នាក់។
- បានធ្វើយុទ្ធនាការផ្សព្វផ្សាយបង្កើនការយល់ដឹងដល់សាធារណជន អំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ និងការតម្រង់ទិសដល់អ្នកចូលរួមនិងសិស្សចំនួន ៣០ ៧១៧នាក់។
- បានធ្វើការហ្វឹកហ្វឺន និងធ្វើតេស្តកូនជាងចំនួន ២១ ០៤៤នាក់ (កើន ៥៥%)។

## ៣-ការអភិវឌ្ឍមុខរបរ និងការងារ

- បានផ្តល់សេវាមុខរបរ និងរកការងារជូនប្រជាពលរដ្ឋក្នុងឆ្នាំ២០១៦ សរុបចំនួន ២១១ ៨៤៧នាក់ (ស្រី១១៦ ៥៨៣នាក់) ក្នុងនោះ៖
  - ការងារក្នុងប្រទេសបានចំនួន ១២៦ ២៧១នាក់ (ស្រី ៨១ ៨៤៥នាក់)។
  - ការងារក្រៅប្រទេសបានចំនួន ៨៥ ៥៧៦នាក់ (ស្រី ៣៤ ៧៣៩នាក់) ក្នុងនោះ៖
    - ✓ ប្រទេសថៃចំនួន ៧៦ ៤៣៣នាក់ (ស្រី ៣១ ៨០៥នាក់)
    - ✓ ប្រទេសកូរ៉េចំនួន ៧ ៣៧១នាក់ (ស្រី ១ ៨៦៨នាក់)
    - ✓ ប្រទេសជប៉ុនចំនួន ១ ៥៦២នាក់ (ស្រី ៨៨៦នាក់)
    - ✓ ប្រទេសម៉ាឡេស៊ីចំនួន ១២៣នាក់ (ស្រី ៩៣នាក់) និង
    - ✓ ប្រទេសសិង្ហបុរីចំនួន ៨៧នាក់ (ស្រី ៨៧នាក់)។

  គិតត្រឹមដំណាច់ខែធ្នូ ឆ្នាំ២០១៦នេះ មានពលករកម្ពុជាដែលកំពុងធ្វើការនៅបរទេសចំនួនប្រមាណជាង ១,១៥លាននាក់ ក្នុងនោះ៖
    - ✓ ប្រទេសថៃចំនួន ១ ០៥៦ ៣៥៨នាក់ (ស្រី ៤២០ ៣៣៦នាក់) ក្នុងនោះអ្នកមិនទាន់មានឯកសារមានចំនួនប្រមាណ ៣១០ ០០០នាក់
    - ✓ ប្រទេសកូរ៉េចំនួន ៤៤ ២២៩នាក់ (ស្រី ៩ ២៨៣នាក់)
    - ✓ ប្រទេសជប៉ុនចំនួន ៣ ៨៩៧នាក់ (ស្រី ៣ ២៦៩នាក់)
    - ✓ ប្រទេសម៉ាឡេស៊ីចំនួន ៤៦ ៥៤១នាក់ (ស្រី ៤០ ០៨៤) និង
    - ✓ ប្រទេសសិង្ហបុរីចំនួន ៤៨៧នាក់ (ស្រី ៤៨៧នាក់)។

ពលករកម្ពុជា ដែលកំពុងធ្វើការងារនៅក្រៅប្រទេសបានផ្ញើថវិកាជូនក្រុមគ្រួសារបានប្រមាណ ជាង ១,៧ពាន់លានដុល្លារអាមេរិក ក្នុង១ឆ្នាំ ព្រមទាំងទទួលបាននូវមុខជំនាញវិជ្ជាជីវៈពេល ត្រលប់មកវិញ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍប្រទេសជាតិ។

- បានប្រមូលផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៦២ ៤២០នាក់ រៀបចំពិព័រណ៍ការងារ វេទិកាការងារ និងសិក្ខាសាលាផ្សព្វផ្សាយ ដោយមានអ្នកចូលរួមសរុបចំនួន ៦៦ ៥៧៥នាក់ ព្រមទាំងផ្តល់សេវាណែនាំដល់អ្នកស្វែងរកការងារចំនួន ២ ៤៤៣នាក់ (ស្រី ១ ៥៣៦នាក់)។
- បានផ្តល់បណ្ណនិងសៀវភៅការងារដល់កម្មករនិយោជិតខ្មែរចំនួន ២២១ ២៧៧នាក់ និងផ្តល់បណ្ណនិងសៀវភៅការងារ និងពន្យារសៀវភៅការងារដល់ជនបរទេសបានចំនួនជាង ២ម៉ឺននាក់។
- បានបង្កើតប្រព័ន្ធគ្រប់គ្រងទិន្នន័យកម្លាំងពលកម្មជនបរទេស ដោយដាក់ឱ្យមានការស្នើសុំកូតា បណ្ណ និងសៀវភៅការងារតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម។

## ៤-ការអភិវឌ្ឍរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយណាដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ

- បានពង្រីកវិសាលភាពបេឡាជាតិរបបសន្តិសុខសង្គមនៅទូទាំង ២៥រាជធានី ខេត្ត ដោយបានចុះបញ្ជីសហគ្រាស គ្រឹះស្ថានថ្មីបានចំនួន ៩៣៥ (កើន ២៤%) ដែលបានគ្របដណ្តប់សមាជិកថ្មីចំនួន ៥៩ ១៩២នាក់ (កើន ៧%)។
- បានអង្កេតរបាយការណ៍ហានិភ័យការងារចំនួន ៣៦ ៧៣៤ នាក់ (កើន ១៣%) ក្នុងនោះ មានកម្មករនិយោជិតរងគ្រោះចំនួន ៣៤ ៥១៣នាក់ (កើន ១៤%) ព្រមទាំងបានផ្តល់តាវកាលិកហានិភ័យការងារចំនួន ៣៦ ៥០៨ឯកសារ (កើន ២៨%) ដល់ជនរងគ្រោះចំនួន ១៥ ៣៣៨នាក់ (កើន ៤៤%)។
- បានអនុវត្តរបបថែទាំសុខភាពចាប់ពីខែមិថុនា ឆ្នាំ២០១៦ ដោយបានពង្រីកដល់សហគ្រាស គ្រឹះស្ថានចំនួន ៦០៣ ដែលមានកម្មករនិយោជិតចំនួន ៦០០ ៨៣១នាក់ និងបន្តពង្រីកនៅទូទាំងប្រទេស។
- ចាប់ពីឆ្នាំ២០០៨-២០១៦ សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជីនៅបេឡាជាតិរបបសន្តិសុខសង្គមមានចំនួន ៨ ៧៣១ គ្រឹះស្ថាន និងមានសមាជិកចំនួន ១ ១៣៦ ២៧១នាក់។
- បានរៀបចំសេចក្តីព្រាងព្រះរាជក្រឹត្យស្តីពី ការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

## ៥-ការពង្រឹងអភិបាលកិច្ចល្អ

- បានខិតខំបង្កើនប្រសិទ្ធភាព និងគុណភាពសេវាសាធារណៈរួមមាន ពង្រឹងយន្តការគ្រប់គ្រងការផ្តល់សេវា ការចរាចរលិខិតឯកសារ ពង្រឹងគុណភាពការិយាល័យច្រកចេញ-ចូលតែមួយ និងដាក់ឱ្យដំណើរការប្រព័ន្ធស្វ័យប្រវត្តិកម្មចំនួន១ប្រព័ន្ធ។
- បានបន្តបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការទាន់ពេលវេលាតាមប្រព័ន្ធធនាគារ។

- បានបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ ដោយបានចូលរួមកៀរគរចំណូលសាធារណៈបានចំនួន ១៦៩%នៃផែនការ និងបានអនុវត្តនីតិវិធីចំណាយបានចំនួន ៩៤% នៃថវិកាសរុប។
- បានបន្តអនុវត្តកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលបំណងគោលនយោបាយ" ដោយរៀបចំថវិកាកម្មវិធីសម្រាប់អនុវត្តយុទ្ធសាស្ត្រអាទិភាពនិងកំណែទម្រង់ទាំង៥ នៃការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០១៤-២០១៨ ភ្ជាប់ទៅនឹងសមិទ្ធកម្មក្នុងកម្មវិធីនីមួយៗ។
- បានបន្តពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិនិងអន្តរជាតិ ដោយបង្កើតឱ្យមានយន្តការសម្របសម្រួលការងារអន្តរជាតិពីគ្រប់អង្គភាពក្រោមឱវាទក្រសួង និងដៃគូនានា។
- បានរៀបចំកម្មវិធីវិនិយោគសាធារណៈ ៣ឆ្នាំរំកិល ផែនការយុទ្ធសាស្ត្រថវិកា ផែនការសកម្មភាពគ្រប់អង្គភាពក្រោមឱវាទ និងរាយការណ៍បន្តទាន់ពេលវេលាតាមវដ្តនៃរបាយការណ៍នីមួយៗ ។
- បានបន្តរកឯកសារថ្មីៗតម្កល់នៅក្នុងបណ្ណាល័យក្រសួងដើម្បីមន្ត្រីធ្វើការសិក្សាស្រាវជ្រាវ។
- បានបន្តពង្រឹងការងារសវនកម្មផ្ទៃក្នុង និងអគ្គាធិការកិច្ច ដោយបង្កើតយន្តការសម្របសម្រួលផ្ទៃក្នុងដើម្បីចុះបេសកកម្មរួមគ្នា។
- បានខិតខំលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមផែនការយុទ្ធសាស្ត្រស្តីពីនារីរតនៈទី៣។

**ខ. ទិសដៅអនុវត្តក្នុងឆ្នាំ២០១៧**

បន្តជំរុញកំណែទម្រង់ផែនការយុទ្ធសាស្ត្រអាទិភាពទាំង៥ នៃការអភិវឌ្ឍវិស័យការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដោយប្រមូលផ្តុំលើសកម្មភាពសំខាន់ៗ មួយចំនួន ដូចខាងក្រោមៈ

១-បន្តពង្រឹងការអនុវត្តបទប្បញ្ញត្តិច្បាប់ និងអនុសញ្ញាអន្តរជាតិខាងការងារ និងរៀបចំធ្វើវិសោធនកម្មច្បាប់ស្តីពីការងារលើចំណុចមួយចំនួនមានជាអាទិ៍ ប្រភេទកិច្ចសន្យាការងារ ការងារវេនយប់ លក្ខខណ្ឌការងារសម្រាប់ស្ត្រី និងការហ្វឹកហ្វឺនកូនជាង ព្រមទាំងរៀបចំតាក់តែងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងវិស័យការងារ សំដៅធានានិងធ្វើឱ្យប្រសើរឡើងនូវលក្ខខណ្ឌការងារ សុខភាពនិងសុវត្ថិភាពការងារ និងភាពសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ។

២-បន្តពង្រឹងសមត្ថភាពរបស់មន្ត្រីអធិការកិច្ចការងារក្នុងការអនុវត្តច្បាប់ស្តីពីការងារ ច្បាប់ស្តីពីសហជីព ច្បាប់ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ ព្រមទាំងលិខិតបទដ្ឋានគតិយុត្តផ្សេងៗទៀត។ សហការជាមួយដៃគូជាតិ និងអន្តរជាតិបើកវគ្គបណ្តុះបណ្តាលដល់ភាគីពាក់ព័ន្ធ ដើម្បីឱ្យយល់ច្បាស់ពីច្បាប់ និងលិខិតបទដ្ឋានគតិយុត្តថ្មីៗពាក់ព័ន្ធនឹងវិស័យការងារ។

៣-បន្តពង្រឹងគុណភាពនៃការធ្វើអធិការកិច្ចការងារ សំដៅបន្តលើកកម្ពស់សិទ្ធិ និងផលប្រយោជន៍របស់កម្មករនិយោជិតនិងនិយោជក និងកែប្រែឥរិយាបថមន្ត្រីអធិការកិច្ចការងារឱ្យជិតស្និទ្ធនឹងសហគ្រាសគ្រឹះស្ថាន និងកម្មករនិយោជិត តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធអធិការកិច្ចការងារ ដោយប្រើប្រព័ន្ធព័ត៌មានវិទ្យា និងប្រព័ន្ធទិន្នន័យដែលអាចផ្ទៀងផ្ទាត់បានភ្លាមៗ ក៏ដូចជាបន្តពង្រឹងកិច្ចសហការជាមួយកម្មវិធីការងារល្អកម្ពុជា តែ

ប្រសើរនៅកម្ពុជារបស់អង្គការ ILO ដើម្បីដាក់ចេញនូវផែនការសកម្មភាពរួមគ្នា និងមានបញ្ជីត្រួតពិនិត្យមួយដែលអាចធ្វើការសំយោគជាមួយគ្នាបាន។

៤-ជំរុញការអនុម័តសេចក្តីព្រាងច្បាប់ស្តីពីនីតិវិធីជម្រះក្តីវិវាទការងារ និងសេចក្តីព្រាងច្បាប់ស្តីពីប្រាក់ឈ្នួលអប្បបរមា ព្រមទាំងបន្តរៀបចំលិខិតបទដ្ឋានគតិយុត្ត សេចក្តីណែនាំ និងសេចក្តីជូនដំណឹងនានាដើម្បីជំរុញការអនុវត្តច្បាប់ដែលពាក់ព័ន្ធនឹងវិស័យការងារ។

៥-បន្តជំរុញការអនុវត្តផែនការសកម្មភាពជាតិស្តីពីការកាត់បន្ថយពលកម្មកុមារ និងការលុបបំបាត់ទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ២០១៦-២០២៥។

៦-បន្តខិតខំដោះស្រាយវិវាទការងារជូនដល់គ្រប់ភាគីពាក់ព័ន្ធឱ្យបានទាន់ពេលវេលា ប្រកបដោយប្រសិទ្ធភាព ព្រមទាំងខិតខំទប់ស្កាត់ការធ្វើកូដកម្ម បាតុកម្មខុសច្បាប់ និងត្រូវអនុវត្តច្បាប់ឱ្យបានម៉ឺងម៉ាត់ ដើម្បីលុបបំបាត់និទណ្ឌភាព និងធានាបាននូវសុខដុមរមនាក្នុងទំនាក់ទំនងវិជ្ជាជីវៈ តាមរយៈការដាក់ឱ្យដំណើរការប្រព័ន្ធទិន្នន័យសម្រាប់កត់ត្រាសាវតារនៃវិវាទការងារ កូដកម្មនិងបាតុកម្មទៅតាមប្រភេទ មុខសញ្ញា ឬភាគីជម្លោះនីមួយៗ។

៧-ដាក់ឱ្យដំណើរការប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីគ្រប់គ្រងទិន្នន័យនៃការចុះបញ្ជីសហជីព និងសមាគមនិយោជក។

៨-បន្តជំរុញការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥។

៩-បន្តជំរុញកិច្ចសហប្រតិបត្តិការលើការប្រើប្រាស់កម្លាំងពលកម្ម ជាមួយបណ្តាប្រទេសដៃគូ ដើម្បីបង្កើតឱកាសការងារបន្ថែម ធានានូវលក្ខខណ្ឌការងារ ការពារសិទ្ធិនិងភាពស្របច្បាប់របស់ពលករកម្ពុជានៅក្រៅប្រទេស ព្រមទាំងបន្តពង្រឹងការផ្តល់បណ្ណការងារដល់ពលករកម្ពុជាទៅធ្វើការនៅក្រៅប្រទេស និងរៀបចំគ្រប់គ្រងពលករទេសន្តរប្រវេសន៍តាមប្រព័ន្ធអេឡិចត្រូនិចដោយសហការជាមួយបណ្តាប្រទេសទទួល។

១០-បន្តកំណត់ប្រាក់ឈ្នួលអប្បបរមាឆ្នាំ២០១៨ សម្រាប់កម្មករនិយោជិតវិស័យវាយនភណ្ឌ កាត់ដេរ និងផលិតស្បែកជើង ទៅតាមលក្ខណវិនិច្ឆ័យ យន្តការ និងកាលវិភាគដែលត្រីភាគីបានកំណត់។

១១-ជំរុញការអនុវត្តមាត្រា១១៦ នៃច្បាប់ស្តីពីការងារ ដែលតម្រូវឱ្យនិយោជកបើកប្រាក់ឈ្នួលរបស់កម្មករយ៉ាងហោចណាស់ ២ដងក្នុង១ខែ។

១២-ជំរុញយន្តការត្រីភាគីពិភាក្សាគ្នា ដើម្បីកំណត់នីតិវិធីទូទាត់ប្រាក់បំណាច់បញ្ចប់កិច្ចសន្យាសម្រាប់កិច្ចសន្យាមានថិរវេលាកំណត់ និងមានថិរវេលាមិនកំណត់។

១៣-បញ្ចប់សេចក្តីព្រាងគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើនការផ្សព្វផ្សាយអំពីសារៈសំខាន់នៃការអប់រំបណ្តុះបណ្តាល និងវិជ្ជាជីវៈ។

១៤-បន្តពង្រឹងគុណភាពកម្មវិធីអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ទាំងរយៈពេលខ្លី និងវែងឱ្យស្របទៅតាមតម្រូវការទីផ្សារការងារនាពេលបច្ចុប្បន្ន និងអនាគតឱ្យបានទូលំទូលាយរហូតដល់តំបន់ដាច់ស្រយាលទូទាំង ២៥រាជធានី ខេត្ត តាមរយៈការបង្កើតមជ្ឈមណ្ឌលថ្នាក់ជាតិ សម្រាប់ធ្វើតេស្តបញ្ជាក់សមត្ថភាព និងប្រកួតប្រជែងជំនាញថ្នាក់ជាតិឱ្យស្របទៅនឹងក្របខ័ណ្ឌគុណវុឌ្ឍិជាតិ ស្តង់ដាជាតិសមត្ថភាព និងកម្មវិធីសិក្សាក្នុងតំបន់។

១៥-បន្តលើកកម្ពស់ការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារប្រកបដោយគុណភាព និងប្រសិទ្ធភាព ដោយពង្រីកយន្តការ “ វេទិកាការងារ” ឱ្យដល់មូលដ្ឋាន ព្រមទាំងគ្រោងបង្កើតមជ្ឈមណ្ឌលការងារចំនួន ២បន្ថែមទៀត។

១៦-បន្តពង្រីកការអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ ផ្នែកថែទាំសុខភាព និងរៀបចំការដាក់ឱ្យដំណើរការរបបសន្តិសុខសង្គមផ្នែកប្រាក់សោធន ព្រមទាំងរៀបចំដាក់ឱ្យអនុវត្តរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជនស្របតាមស្មារតីព្រះរាជក្រឹត្យលេខ នស/រកត/០២១៧/០៧៨ ចុះថ្ងៃទី០១ ខែកុម្ភៈ ឆ្នាំ២០១៧ ស្តីពីការបង្កើតរបបសន្តិសុខសង្គមផ្នែកហានិភ័យការងារសម្រាប់មន្ត្រីរាជការសាធារណៈ និងផ្នែកថែទាំសុខភាពសម្រាប់មន្ត្រីសាធារណៈ អតីតមន្ត្រីរាជការ និងអតីតយុទ្ធជន។

១៧-ធ្វើវិសោធនកម្មច្បាប់ស្តីពីរបបសន្តិសុខសង្គមដើម្បីឱ្យស្របតាមតម្រូវការវិវត្តរបស់សង្គម។

១៨-បង្កើនការផលិតស្ព័តអប់រំ និងការផ្សព្វផ្សាយអំពីសុវត្ថិភាពចរាចរ ការបង្ការទប់ស្កាត់គ្រោះថ្នាក់ការងារនៅកន្លែងធ្វើការ និងការជួលសន្លប់។

១៩-បង្កើតវិទ្យាស្ថានការងារដើម្បីធ្វើវិក្រឹត្យការ និងបណ្តុះបណ្តាលដល់មន្ត្រីអធិការកិច្ចការងារដើម្បីបំពេញនិតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ និងដល់សាធារណជន។

២០-ពង្រឹងគុណភាពច្រកចេញ-ចូលតែមួយ ដើម្បីបង្កើនប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ និងការផ្តល់បណ្ណការងារ សៀវភៅការងារជនបរទេស និងជនកម្ពុជា តាមប្រព័ន្ធអេឡិចត្រូនិច។

២១-ដាក់ដំណើរការមជ្ឈមណ្ឌលទំនាក់ទំនងតាមបណ្តាញទូរសព្ទដោយឥតគិតថ្លៃដល់សាធារណជន **(Call Centre)** តាមរយៈទូរសព្ទលេខ ១២៩៧ នៅក្នុងខែមេសា ឆ្នាំ២០១៧ ដើម្បីផ្តល់ព័ត៌មានបឋមពាក់ព័ន្ធនឹងច្បាប់ស្តីពីការងារ ការដោះស្រាយវិវាទការងារ កូដកម្ម ការធ្វើទេសន្តរប្រវេសន៍ការងារ ព័ត៌មានទីផ្សារការងារ ព័ត៌មានវគ្គនិងជំនាញបណ្តុះបណ្តាលវិជ្ជាជីវៈ សេវាបេឡាជាតិរបបសន្តិសុខសង្គម។ល។

២២-ពង្រឹងការផ្តល់ព័ត៌មានតាមគេហទំព័ររបស់ក្រសួង **www.mlvt.gov.kh** និងបណ្តាញទំនាក់ទំនងសង្គម **https://www.facebook.com/mlvt.gov.kh** ជាមួយសាធារណជន។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមសាធារណជន មេត្តាជ្រាបជាព័ត៌មាន។

*រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១៧*